# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ   សាសនា   ព្រះមហាក្សត្រ

# ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

## របាយការណ៍ការអនុវត្តសេចក្តីសម្រេចចិត្តលេខ២០០៩/២៦

## របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ

## ស្តីពី

## គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិនិងអន្តរជាតិ

## ដើម្បីកំណែទម្រង់យុត្តិធម៌កុមារ

ខែកក្កដា  ឆ្នាំ២០១០

រៀបចំដោយ :

ឧបត្ថម្ភការបោះពុម្ពដោយ  :

unicef

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាជាសមាជិកអង្គការសហប្រជាជាតិនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ និងបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩ ក្រុមប្រឹក្សា សេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសម្រេចចិត្តលេខ ២០០៩/២៦ ក្រោមប្រធានបទ **"គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិនិងអន្តរជាតិ ដើម្បីកំណែទម្រង់យុត្តិធម៌កុមារ ពិសេស តាមរយៈការសម្របសម្រួលដែលកាន់តែប្រសើរឡើងខាងជំនួយបច្ចេកទេស"**។ សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ប្រទេសកម្ពុជាបានផ្តល់របាយការណ៍ជូនការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អង្គការ សហប្រជាជាតិមុនថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសក្នុងការអនុវត្តសេចក្តីសម្រេចចិត្ត សម្រាប់ដាក់ក្នុងសម័យប្រជុំលើកទី ២០ នៃគណៈកម្មាធិការបង្ការបទល្មើស និងយុត្តិធម៌ព្រហ្មទណ្ឌ ដែលនឹងប្រារព្ធធ្វើនៅខែមេសា ឆ្នាំ២០១១ ខាងមុខ ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំរបាយការណ៍លទ្ធផលនៃការអនុវត្តរបស់ក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដែលឆ្លុះបញ្ចាំងអំពីកំណែទម្រង់គោលនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ពាក់ព័ន្ធនឹងយុត្តិធម៌កុមារ កំណែទម្រង់តុលាការ នីតិវិធីនិងតុលាការ កុមារមេត្រី ការអង្កេតស្រាវជ្រាវ ការពង្រឹងសមត្ថភាពស្ថាប័ននិងអ្នកជំនាញ សេវានិងជំនួយដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ការបង្ការនិងការបង្វែរ ការលើកកម្ពស់ការយល់ដឹង ការបង្កើតប្រព័ន្ធទិន្នន័យនិងការគ្រប់គ្រងព័ត៌មាន ការត្រួតពិនិត្យតាមដាន សហប្រតិបត្តិការនិងការសម្របសម្រួល ដោយបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ បន្ទាប់មកក៏បានដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដើម្បីពិនិត្យនិងសម្រេចនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១០ និងបានផ្ញើរបាយ

ការណ៍នេះជូនការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អង្គការសហប្រជាជាតិតាមរយៈក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១០ ។

ក្រោមការដឹកនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានជំរុញការលើកកម្ពស់ការអនុវត្តសិទ្ធិជាមូលដ្ឋានទាំង៤របស់កុមារ ដោយបានបង្កើតច្បាប់ ផែនការជាតិ យន្តការជាតិ កម្មវិធី និងបានដាក់ចេញនូវវិធានការជាច្រើន ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ និងផ្តល់យុត្តិធម៌ដល់កុមារស្របតាមរដ្ឋធម្មនុញ្ញ គោលការណ៍នីតិរដ្ឋ និងអនុសញ្ញាអន្តរជាតិ ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំបោះពុម្ពរបាយការណ៍នេះជាភាសាខ្មែរនិងអង់គ្លេស សម្រាប់ផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ននិងអង្គការពាក់ព័ន្ធ ក្នុងគោលបំណងដើម្បីឱ្យក្រសួង ស្ថាប័ននិងអង្គការពាក់ព័ន្ធបានទទួលជ្រាបអំពីលទ្ធផលនៃការអនុវត្តសេចក្តីសម្រេចចិត្តលេខ២០០៩/២៦របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចនៃអង្គការសហប្រជាជាតិកន្លងមក ដើម្បីរៀបចំកម្មវិធីនានាដែលជាឧត្តមប្រយោជន៍កុមារបន្តទៀត ។

សូមថ្លែងអំណរគុណចំពោះសមាជិក សមាជិកាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារតំណាងក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ ដែលធ្វើឱ្យខ្លឹមសារនៃរបាយការណ៍មានភាពសុក្រិត្យ និងសូមថ្លែងអំណរគុណចំពោះអង្គការយូនីសេហ្វ ដែលបានឧបត្ថម្ភផ្នែកបច្ចេកទេសនិងថវិកាដល់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងការរៀបចំរបាយការណ៍នេះ ។

*រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១០*

**ជ. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**ប្រធាន**

# មាតិកា

ទំព័រ


ការិយាល័យប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អង្គការសហប្រជាជាតិ ........ i

I. សេចក្តីផ្តើម ........ ១

II. កំណែទម្រង់គោលនយោបាយនិងច្បាប់ទាក់ទងនឹងយុត្តិធម៌កុមារ ........ ៣

III. កំណែទម្រង់តុលាការ ........ ១២

IV. នីតិវិធីកុមារមេត្រីនិងតុលាការកុមារមេត្រី ........ ១៣

V. ការអង្កេតស្រាវជ្រាវទាក់ទងនឹងកុមារ ........ ១៤

VI. ការពង្រឹងសមត្ថភាពស្ថាប័ននិងអ្នកអនុវត្តច្បាប់ ........ ១៤

VII. សេវានិងជំនួយ ........ ១៦

VIII. ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ការបង្ការ និងការបង្វែរ ........ ១៩

IX. ការលើកកម្ពស់ការយល់ដឹង ........ ២១

X. ការបង្កើតប្រព័ន្ធទិន្នន័យនិងការគ្រប់គ្រងព័ត៌មាន ........ ២២

XI. ការត្រួតពិនិត្យតាមដាន ........ ២៣

XII. សហប្រតិបត្តិការនិងការសម្របសម្រួល ........ ២៤

XIII. សន្និដ្ឋាន ........ ២៧

UNODC

**ការិយាល័យប្រឆាំងគ្រឿងញៀន**

**និងឧក្រិដ្ឋកម្មរបស់អង្គការសហប្រជាជាតិ**

លេខយោង : CU ២០០៨/១៥០

អគ្គលេខាធិការអង្គការសហប្រជាជាតិ សូមសំដែងនូវការកោតសរសើរចំពោះរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងមានកិត្តិយសចំពោះការយកចិត្តទុកដាក់របស់រដ្ឋាភិបាលចំពោះសេចក្តីសំរេចចិត្តលេខ ២០០៩/២៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចក្រោមប្រធានបទ " គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិ និងអន្តរជាតិដើម្បីកំណែទំរង់យុត្តិធម៌កុមារ ពិសេសតាមរយៈការសម្របសម្រួល ដែលកាន់តែប្រសើរឡើងខាងជំនួយផ្នែកបច្ចេកទេស" ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩។ ឯកសារចម្លងនៃសេចក្តីសំរេចចិត្តនេះ មានជូនភ្ជាប់មកជាមួយ។

ក្នុងកថាខណ្ឌ១ នៃសេចក្តីសំរេចចិត្តក្រុមប្រឹក្សាបានជំរុញរដ្ឋសមាជិកឱ្យយកចិត្តទុកដាក់ជាពិសេស ឬបង្កើនការយកចិត្តទុកដាក់ចំពោះបញ្ហាយុត្តិធម៌កុមារ និងធ្វើការពិចារណាទៅលើលិខិតុបករណ៍អន្តរជាតិដែលនៅជាធរមានព្រមទាំង វិធាននិងបទដ្ឋាននានារបស់អង្គការសហប្រជាជាតិសំរាប់ការប្រព្រឹត្តលើកុមារទំនាស់នឹងច្បាប់តាមការសមស្រប ជាពិសេស អនីតិជនដែលត្រូវបានដកហូតសេរីភាពរបស់ពួកគេ ជនរងគ្រោះនិងសាក្សីនៃបទឧក្រិដ្ឋជាកុមារ ដោយពិចារណាផងដែរទៅលើអាយុ ភេទ ស្ថានភាពសង្គម និងតំរូវការការអភិវឌ្ឍន៍របស់កុមារទាំងនោះ។

ក្នុងកថាខណ្ឌ២ ក្រុមប្រឹក្សាបានអញ្ជើញរដ្ឋសមាជិក តាមការសមស្របឱ្យដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព ជាតិដ៏ទូលាយស្តីពីការបង្ការបទល្មើស និងកំណែទំរង់យុត្តិធមិកុមារ ដែលជាប់ទាក់ទងជាពិសេសជាមួយនឹងការទប់ស្កាត់កុមារពីការជាប់ទាក់ទងនឹងបទល្មើស ការធានានូវសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ជាពិសេសសំរាប់កុមារក្រីក្រ និងការកាត់បន្ថយនូវការប្រើប្រាស់នៃការឃុំខ្លួន និងថេរៈវេលានៃការឃុំខ្លួនកុមារ ជាពិសេសនៅក្នុងដំណាក់កាលមុនការកាត់សេចក្តី រួមមាន តាមរយៈការប្រើប្រាស់នូវការបង្វែរ ការផ្តល់នូវយុត្តិធមិឡើងវិញ និងជំរើសផ្សេងៗទៀតក្រៅពីការឃុំខ្លួន ការធ្វើសមាហរណកម្មកុមារទំនាស់នឹងច្បាប់ទៅក្នុងសហគមន៍របស់ពួកគេ និងនីតិវិធីគាំពារកុមារ សំរាប់កុមារទាំងអស់ ដែលទាក់ ទងទៅនឹងប្រព័ន្ធយុត្តិធិម។

ជាងនេះទៅទៀត នៅក្នុងកថាខណ្ឌ៣ រដ្ឋសមាជិកនិងស្ថាប័នពាក់ព័ន្ធរបស់ខ្លួនត្រូវបានអញ្ជើញឱ្យចូលរួមអនុម័តវិធីសាស្ត្រដ៏ទូលាយមួយចំពោះកំណែទំរង់យុត្តិធមិកុមារតាមការសមស្រប រួមមាន តាមរយៈកំណែទំរង់គោលនយោបាយ កំណែទំរង់ច្បាប់ ការបង្កើតនូវប្រព័ន្ធនៃការប្រមូលទិន្នន័យ និងគ្រប់គ្រងព័តិមាន ការពង្រឹងសមត្ថភាពស្ថាប័ន រួមទាំង ដល់បុគ្គលិកសង្គមកិច្ច និងអ្នកផ្តល់ជំនួយផ្នែកច្បាប់ ការកសាងចំណេះដឹងនិងការត្រួតពិនិត្យ និងការបង្កើតនីតិវិធី និងស្ថាប័នគាំពារកុមារ។

ឯកឧត្តម ហោ ណាំហុង
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
នៃព្រះរាជាណាចក្រកម្ពុជា

ក្នុងកថាខណ្ឌ៤ ក្រុមប្រឹក្សាក៏បានលើកទឹកចិត្តដល់រដ្ឋសមាជិកតាមការសមស្របដើម្បីធ្វើការស្រាវជ្រាវបែបវិទ្យាសាស្ត្រទាក់ទងនឹងកុមារទំនាស់នឹងច្បាប់តាមតំបន់ដែលជាបរិយាកាសសង្គមរបស់ពួកគេ និងកត្តាគ្រោះថ្នាក់ដទៃទៀត និងវិធានការណ៍ទាំងឡាយសំរាប់ការស្តារឡើងវិញនូវវិស័យសង្គមកិច្ច និងការធ្វើសមាហរណកម្មទៅក្នុងសង្គមឡើងវិញ ហើយនៅក្នុងកថាខណ្ឌ៥ បានអញ្ជើញរដ្ឋសមាជិកតាមការសមស្របឱ្យប្រើប្រាស់ឧបករណ៍ជំនួយបច្ចេកទេស ដែលបង្កើតដោយក្រុមអន្តរទីភ្នាក់ងារទទួលបន្ទុកយុត្តិធមិកុមារ (Interagency Panel on Juvenile Justice) និងដោយសមាជិកទាំងអស់របស់ខ្លួន និងដើម្បីស្វែងរកការណែនាំ និងជំនួយបច្ចេកទេសនៅក្នុងវិស័យយុត្តិធមិកុមារ ពីសមាជិកនានារបស់ក្រុមអន្តរទីភ្នាក់ងារ ដើម្បីរៀបចំអនុវត្តនិងឃ្លាំមើលគោលនយោបាយរួមនៃយុត្តិធមិកុមារ។

នៅក្នុងកថាខណ្ឌ៦ ក្រុមប្រឹក្សាបានលើកទឹកចិត្តរដ្ឋសមាជិក និងទីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិឱ្យផ្តល់ធនធានគ្រប់គ្រាន់ដល់អគ្គលេខាធិការដ្ឋាននៃក្រុមអន្តរទីភ្នាក់ងារទទួលបន្ទុកយុត្តិធមិកុមារ និងសមាជិកនានារបស់ក្រុមអន្តរទីភ្នាក់ងារដើម្បីអោយពួកគេអាចបន្តផ្តល់ជំនួយបច្ចេកទេសកាន់តែប្រសើរឡើងតាមការស្នើសុំដល់រដ្ឋសមាជិកជាពិសេស ដល់រដ្ឋណាដែលបានបង្ហាញពីសេចក្តីត្រូវការខាងជំនួយបច្ចេកទេសអនុលោមតាមសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ចលេខ ២០០៧/២៣ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧។

ក្នុងកថាខណ្ឌ៧ ក្រុមប្រឹក្សាបានស្នើដល់សមាជិកទាំងអស់នៃក្រុមអន្តរទីភ្នាក់ងារទទួលបន្ទុកយុត្តិធមិកុមារឱ្យបន្តផ្តល់ជំនួយដល់រដ្ឋសមាជិក តាមការស្នើសុំនិងយោង

ទៅតាមធនធានដែលមាននៅក្នុងវិស័យយុត្តិធម៌កុមារ រួមទាំង ការអនុវត្តតាមអនុសាសន៍ដែលមាននៅក្នុងការសិក្សារបស់អង្គការសហប្រជាជាតិស្តីពីអំពើហឹង្សាប្រឆាំងកុមារ និងការបង្កើតនូវប្រព័ន្ធនៃការប្រមូលទិន្នន័យថ្នាក់ជាតិ និងប្រព័ន្ធព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌទាក់ទងនឹងកុមារទំនាស់នឹងច្បាប់ ដោយប្រើជាមគ្គុទ្ទេសក៍នូវសៀវភៅក្បួនខ្នាតសំរាប់ការវាស់វែងសូចនាករយុត្តិធម៌កុមារ និងនៅក្នុងកថាខណ្ឌ៨ បានលើកទឹកចិត្តសមាជិកទាំងអស់នៃក្រុមអន្តរទីភ្នាក់ងារទទួលបន្ទុកយុត្តិធម៌កុមារ ឱ្យបង្កើនថែមទៀតនូវកិច្ចសហប្រតិបត្តិការរបស់ពួកគេចែករំលែកព័ត៌មានគ្នា និងប្រមូលផ្តុំសមត្ថភាពនិងធនធានរបស់ពួកគេដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី រួមទាំងតាមរយៈការធ្វើកម្មវិធីរួមគ្នាតាមការសមស្រប និងការបង្កើតនូវឧបករណ៍រួមនិងការលើកកំពស់ការយល់ដឹង។

នៅទីបញ្ចប់ ក្នុងកថាខណ្ឌ១០ ក្រុមប្រឹក្សាបានស្នើដល់អគ្គលេខាធិការឱ្យរាយការណ៍ជូនគណៈកម្មាធិការបង្ការបទល្មើសនិងយុត្តិធម៌ព្រហ្មទណ្ឌនៅឯសម័យប្រជុំលើកទី២០ ស្តីពីការអនុវត្តសេចក្តីសំរេចចិត្តដែលបានលើកឡើងខាងលើ។

ដើម្បីឱ្យអគ្គលេខាធិការអាចប្រមូលព័ត៌មានស្តីពីបញ្ហា ដែលបានលើកឡើងនៅក្នុងសេចក្តីសំរេចចិត្តនេះ និងដើម្បីប្រតិបត្តិតាមកាតព្វកិច្ចធ្វើរបាយការណ៍សំរាប់សម័យប្រជុំលើកទី២០នៃគណៈកម្មាធិការបង្ការបទល្មើសនិងយុត្តិធម៌ព្រហ្មទណ្ឌដែលនឹងប្រារព្ធធ្វើនៅខែមេសា ឆ្នាំ២០១១ រដ្ឋាភិបាលត្រូវបានអញ្ជើញឱ្យផ្តល់ព័ត៌មានជារបាយការណ៍ជូនការិយាល័យប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មរបស់អង្គការសហប្រជាជាតិស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការអនុវត្តសេចក្តីសំរេចចិត្តនេះ។ ព័ត៌មាននេះ

ត្រូវតែបានបញ្ជូនទៅអង្គភាពយុត្តិធម៌ និងសុចរិតភាព/កំរងយុត្តិធម៌តាមប្រធានបទ នៃផ្នែកប្រតិបត្តិការរបស់ការិយាល័យប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្មអង្គការសហប្រជាជាតិយ៉ាងយូរបំផុតត្រឹមថ្ងៃទី **១ ខែកក្កដា ឆ្នាំ២០១០** តាមរយៈប្រអប់សំបុត្រ P.O.Box 500,1400 Vienna អូទ្រីស ហ្វាក់ : +43-1-2606-5866 ឬឆ្លើយតបតាម E-mail: criminal.justice@unodc.org

ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩

*រំលឹកឡើងវិញ* នូវសេចក្តីសំរេចចិត្តលេខ២០០៧/២៣ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីកំណែទំរង់យុត្តិធមិកុមារ ។

*ស្វាគមន៍* របាយការណ៍របស់អគ្គលេខាធិការស្តីពីការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិសំរាប់កំណែទំរង់យុត្តិធមិកុមារ ជាពិសេសតាមរយៈជំនួយបច្ចេកទេស និងការសម្របសម្រួលតាមប្រព័ន្ធដ៏ទូលាយរបស់អង្គការសហប្រជាជាតិ ដែលបានកែលំអឱ្យប្រសើរឡើង ។

*កត់សំគាល់ថា* យោងតាមរបាយការណ៍នេះ រដ្ឋខ្លះបានរាយការណ៍ពីការអនុវត្តវិធានការដ៏មានប្រសិទ្ធភាព ដើម្បីកាត់បន្ថយការប្រើប្រាស់ទោសដាក់ពន្ធនាគារ និងការឃុំខ្លួនមុនការកាត់សេចក្តីលើអនីតិជនទំនាស់នឹងច្បាប់  ខណៈពេលដែលរដ្ឋជាច្រើននៅតែប្រើការដកហូតសេរីភាពថាជាច្បាប់ ជាជាងការលើកលែង ។

*កត់សំគាល់ផងដែរ* នូវការកើនឡើងនៃគ្រឹះស្ថានឯកទេសនិងវិជ្ជាជីវៈ និងការផ្តល់ការបណ្តុះបណ្តាលសមស្រប  និងការបណ្តុះបណ្តាលឡើងវិញសមស្របនៅក្នុងវិស័យនេះ និងការអភិវឌ្ឍន៍នូវវិធានការបង្វែរ កម្មវិធីស្តារយុត្តិធមិឡើងវិញ និងកម្មវិធីជំរើសផ្សេងៗក្រៅពីការឃុំខ្លួន ដែលបានរាយការណ៍ដោយរដ្ឋសមាជិក និងលើកទឹកចិត្តដល់រដ្ឋផ្សេងទៀតឱ្យអនុម័តយកកម្មវិធីដូចគ្នានេះដែរ ។

*ទទួលស្គាល់ដោយពេញចិត្ត* ការងាររបស់ក្រុមអន្តរទីភ្នាក់ងារទទួលបន្ទុកយុត្តិធមិកុមារ និងសមាជិករបស់ខ្លួន នាយកដ្ឋានប្រតិបត្តិការរក្សាសន្តិភាពនៃអគ្គលេខាធិការដ្ឋាន  ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ការិយាល័យសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មនិងគ្រឿងញៀន  មូលនិធិសហប្រជាជាតិដើម្បីកុមារ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ វិទ្យាស្ថានស្រាវជ្រាវយុត្តិធមិ និងឧក្រិដ្ឋកម្មអន្តរតំបន់នៃសហប្រជាជាតិ គណៈកម្មាធិការសិទ្ធិកុមារ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ជាពិសេស ការសម្របសម្រួលនៃការផ្តល់យោបល់ និងជំនួយបច្ចេក

ទេសនៅក្នុងវិស័យយុត្តិធម៌កុមារ និងការចូលរួមយ៉ាងសកម្មពីសង្គមស៊ីវិលក្នុងកិច្ចការទាំងអស់នេះ ។

*ចងចាំថា* វិធីសាស្ត្ររបស់អង្គការសហប្រជាជាតិចំពោះយុត្តិធម៌សំរាប់កុមារ ដែលមានបញ្ជាក់ក្នុងកំណត់ត្រាណែនាំរបស់អគ្គលេខាធិការ ចុះខែកញ្ញា ឆ្នាំ២០០៨ មានគោលបំណងអនុវត្តឱ្យបានពេញលេញនៃបទដ្ឋានអង្គការសហប្រជាជាតិ និងវិធានសំរាប់កុមារទាំងអស់ ដែលមានទំនាក់ទំនងជាមួយផ្នែកយុត្តិធម៌ និងប្រព័ន្ធពាក់ព័ន្ធផ្សេងទៀតក្នុងនាមជាជនរងគ្រោះ សាក្សី ឬជនល្មើសដែលត្រូវគេចោទប្រកាន់ ឬក្នុងកាលៈទេសៈផ្សេងៗទៀត ដែលអន្តរាគមន៍តាមផ្លូវច្បាប់តំរូវ ។

១-*ជំរុញ* រដ្ឋសមាជិកឱ្យយកចិត្តទុកដាក់ជាពិសេសចំពោះ ឬបង្កើនការយកចិត្តទុកដាក់ដល់បញ្ហាយុត្តិធម៌កុមារ និងធ្វើការពិចារណាទៅលើលិខិតុបករណ៍អន្តរជាតិទាំងឡាយដែលនៅជាធរមានតាមការសមស្រប ព្រមទាំងវិធាននិងបទដ្ឋាននានារបស់អង្គការសហប្រជាជាតិសំរាប់ការប្រព្រឹត្តលើកុមារទំនាស់នឹងច្បាប់ ជាពិសេសអនីតិជនដែលត្រូវបានដកហូតសេរីភាពជនរងគ្រោះនិងសាក្សីជាអនីតិជននៃបទល្មើស ដោយពិចារណាផងដែរទៅលើអាយុ ភេទ ស្ថានភាពសង្គម និងតំរូវការអភិវឌ្ឍន៍របស់កុមារទាំងនោះ ។

២-*អញ្ជើញ* រដ្ឋសមាជិកឱ្យចូលរួមតាមការសមស្រប អនុម័តផែនការសកម្មភាពជាតិរួមស្តីពីការបង្ការបទល្មើសនិងកំណែទំរង់យុត្តិធម៌កុមារ ដែលជាប់ទាក់ទងជាពិសេសជាមួយការទប់ស្កាត់កុមារពីការជាប់ទាក់ទងនឹងបទល្មើស ការធានានូវសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ ជាពិសេសសំរាប់កុមារក្រីក្រ និងការកាត់បន្ថយនូវការប្រើប្រាស់នៃការឃុំខ្លួន និងថេរៈវេលានៃការឃុំខ្លួនកុមារ ជាពិសេសនៅក្នុងដំណាក់កាលមុនការកាត់សេចក្តី រួមមាន តាមរយៈការប្រើប្រាស់នូវការបង្វែរការផ្តល់នូវយុត្តិធម៌ឡើងវិញ និងជំរើសផ្សេងៗទៀតក្រៅពីការឃុំខ្លួន ការធ្វើសមាហរណកម្មកុមារទំនាស់

នឹងច្បាប់ទៅ ក្នុងសហគមន៍របស់ពួកគេ និងនីតិវិធីគាំពារកុមារសំរាប់កុមារទាំងអស់ដែលទាក់ទងទៅនឹងប្រព័ន្ធយុត្តិធម ។

៣-*អញ្ជើញ* រដ្ឋសមាជិក និងស្ថាប័នពាក់ព័ន្ធរបស់ខ្លួនផងដែរឱ្យចូលរួមអនុម័តវិធីសាស្ត្រដ៏ទូលាយមួយ ចំពោះកំណែទំរង់យុត្តិធមិកុមារតាមការសមស្រប រួមមានតាមរយៈកំណែទំរង់គោលនយោបាយ កំណែទំរង់ច្បាប់ ការបង្កើតនូវប្រព័ន្ធនៃការប្រមូលទិន្នន័យនិងគ្រប់គ្រងព័តិមាន ការពង្រឹងសមត្ថភាពស្ថាប័ន រួមទាំងដល់បុគ្គលិកសង្គមកិច្ចនិងអ្នកផ្តល់ជំនួយផ្នែកច្បាប់ ការកសាងចំណេះដឹងនិងការត្រួតពិនិត្យ និងការបង្កើតនីតិវិធីនិងស្ថាប័នគាំពារកុមារ ។

៤-*លើកទឹកចិត្ត* រដ្ឋសមាជិកតាមការសមស្របឱ្យធ្វើការស្រាវជ្រាវបែបវិទ្យាសាស្ត្រទាក់ទងនឹងកុមារទំនាស់នឹងច្បាប់ តាមតំបន់ដែលជាបរិយាកាសសង្គមរបស់ពួកគេនិងកត្តាគ្រោះថ្នាក់ដទៃទៀត និងវិធានការណ៍ទាំងឡាយសំរាប់ការស្តារឡើងវិញនូវវិស័យសង្គមកិច្ច និងការធ្វើសមាហរណកម្មទៅក្នុងសង្គមឡើងវិញ ។

៥-*អញ្ជើញ* រដ្ឋសមាជិកតាមការសមស្របឱ្យប្រើប្រាស់ឧបករណ៍ជំនួយបច្ចេកទេសដែលបង្កើតដោយក្រុមអន្តរទីភ្នាក់ងារទទួលបន្ទុកយុត្តិធមិកុមារ (Interagency Panel on Juvenile Justice) និងដោយសមាជិកទាំងអស់របស់ខ្លួន និងដើម្បីស្វែងរកការណែនាំនិងជំនួយបច្ចេកទេស នៅក្នុងវិស័យយុត្តិធមិកុមារ ពីសមាជិកនានារបស់ក្រុមអន្តរទីភ្នាក់ងារដើម្បីរៀបចំអនុវត្ត និងឃ្លាំមើលគោលនយោបាយរួមនៃយុត្តិធមិកុមារ ។

៦-*លើកទឹកចិត្ត* រដ្ឋសមាជិកនិងទីភ្នាក់ងារផ្តល់ជំនួយអន្តរជាតិឱ្យផ្តល់ធនធានគ្រប់គ្រាន់ ដល់អគ្គលេខាធិការដ្ឋាននៃក្រុមអន្តរទីភ្នាក់ងារទទួលបន្ទុកយុត្តិធមិកុមារ និងសមាជិកនានារបស់ខ្លួន ដើម្បីអោយពួកគេអាចបន្តផ្តល់ជំនួយបច្ចេកទេសកាន់តែប្រសើរឡើងតាមការស្នើសុំដល់រដ្ឋសមាជិក ជាពិសេស ដល់រដ្ឋណាដែលបានបង្ហាញពី

សេចក្តីត្រូវការខាងជំនួយបច្ចេកទេស  អនុលោមតាមសេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច លេខ២០០៧/២៣ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០០៧។

៧-*អញ្ជើញ* សមាជិកទាំងអស់នៃក្រុមអន្តរទីភ្នាក់ងារទទួលបន្ទុកយុត្តិធម៌កុមារឱ្យបន្តផ្តល់ជំនួយដល់រដ្ឋសមាជិកតាមការស្នើសុំ  និងយោងទៅតាមធនធានដែលមាននៅក្នុងវិស័យយុត្តិធម៌កុមារ រួមទាំង ការអនុវត្តតាមអនុសាសន៍ដែលមាននៅក្នុងការសិក្សារបស់អង្គការសហប្រជាជាតិស្តីពីអំពើហឹង្សាប្រឆាំងកុមារ  និងការបង្កើតនូវប្រព័ន្ធនៃការប្រមូលទិន្នន័យថ្នាក់ជាតិ   និងប្រពន្ធ័ព័ត៌មានយុត្តិធម៌ព្រហ្មទណ្ឌទាក់ទងនឹងកុមារទំនាស់នឹងច្បាប់ដោយប្រើជាមគ្គុទ្ទេសក៍នូវ *សៀវភៅក្បួនខ្នាតសំរាប់ការវាស់វែងសូចនាករយុត្តិធម៌កុមារ* ។

៨-*លើកទឹកចិត្ត* សមាជិកទាំងអស់នៃក្រុមអន្តរទីភ្នាក់ងារទទួលបន្ទុកយុត្តិធម៌កុមារឱ្យបង្កើនថែមទៀតនូវកិច្ចសហប្រតិបត្តិការរបស់ពួកគេ  ចែករំលែកព័ត៌មានគ្នានិងប្រមូលផ្តុំសមត្ថភាព និងធនធានរបស់ពួកគេ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីរួមទាំងតាមរយៈការធ្វើកម្មវិធីរួមគ្នា តាមការសមស្របនិងការបង្កើតនូវឧបករណ៍រួមនិងការលើកកំពស់ការយល់ដឹង។

៩-*ស្នើដល់*  អគ្គលេខាធិការឱ្យរាយការណ៍ជូនគណៈកម្មាធិការបង្ការបទល្មើសនិងយុត្តិធម៌ព្រហ្មទណ្ឌនៅឯសម័យប្រជុំលើកទី២០  ស្តីពីការអនុវត្តសេចក្តីសំរេចចិត្តដែលបានលើកឡើងខាងលើ។

សម័យប្រជុំពេញអង្គលើកទី៤៤
ថ្ងៃទី៣០  ខែកក្កដា  ឆ្នាំ២០០៩

## I. សេចក្តីផ្តើម

**១-** ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ បង្ហាញថា ប្រជារាស្ត្ររបស់ប្រទេសកម្ពុជាបានកើនឡើង ១,៩៦ លាននាក់ ក្នុងរយៈពេល ១០ឆ្នាំ កន្លងមក គឺកើនពី ១១,៤ លាននាក់ ដល់ ១៣,៤ លាននាក់ ក្នុងឆ្នាំ២០០៨ ។ ដង់ស៊ីតេប្រជាជនក៏កើនឡើងពី ៦៤នាក់ ទៅ ៧៥នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ [១] ។ ប្រជារាស្ត្រប្រហែលពាក់កណ្តាលមានអាយុក្រោម ២០ឆ្នាំ ក្នុងនោះកុមារអាយុក្រោម ១៨ឆ្នាំ មានប្រហែល ៤១% នៃចំនួនប្រជាជនសរុប ។ អត្រានៃភាពក្រីក្របានថយចុះពី ៤៧% ក្នុងអំឡុងពេលជាងមួយទសវត្សរ៍កន្លងមកនៅត្រឹម ២៧% គិតត្រឹមឆ្នាំ២០១០ ដោយសារប្រទេសមានសន្តិភាព និងការអនុវត្តគោលនយោបាយលើកទឹកចិត្តដល់ពាណិជ្ជកម្ម និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ។ ការកើនឡើងតម្លៃប្រេង និងម្ហូបអាហារមានផលប៉ះពាល់ខ្លាំងដល់គ្រួសារនិងជនក្រីក្រ ជាពិសេស ស្ត្រីនិងកុមារ ។

**២-** វិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកលលោកបានធ្វើឱ្យមានការថយចុះតម្រូវការទំនិញដែលនាំចេញពីកម្ពុជា និងបានធ្វើឱ្យកើនឡើងហានិភ័យម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការវិវត្តនានានៅក្នុងពិភពលោកបានធ្វើឱ្យកម្ពុជាជួបបញ្ហាប្រឈមនានា ដែលមិនបានរំពឹងទុកជាមុន។ បញ្ហាទាំងនេះ ធ្វើឱ្យគ្រួសារងាយនឹងបែកបាក់ដោយសារការស្វែងរកជីវភាពរស់នៅ និងធ្វើឱ្យកុមារស្ថិតក្នុងស្ថានភាពងាយរងគ្រោះពីការរំលោភបំពាន អំពើហិង្សា និងការកេងប្រវ័ញ្ច។ ការមិនយកចិត្តទុកដាក់ ការខ្វះខាតសេវាគាំទ្រនាំឱ្យកុមារស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដោយរស់នៅតាមចិញ្ចើមថ្នល់ ឬប្រព្រឹត្តល្មើស

---

[១] ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ (វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ )

នឹងច្បាប់ ។ រាជរដ្ឋាភិបាល បានចាត់វិធានការជាប្រព័ន្ធ និងតាមលំដាប់លំដោយដើម្បីកាត់បន្ថយឱ្យនៅកម្រិតទាបបំផុតផលប៉ះពាល់អវិជ្ជមានរបស់វិបត្តិហិរញ្ញវត្ថុនិង សេដ្ឋកិច្ចសកលលោកមកលើប្រព័ន្ធហិរញ្ញវត្ថុនិងសេដ្ឋកិច្ចរបស់កម្ពុជា និងការពារបណ្ដាសមិទ្ធផលដែលទទួលបាន [២] ។

**៣-** ក្រោយពីសង្គ្រាមស៊ីវិលជាង២ទស្សវត្សរ៍ ព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្ដើមបង្កើតប្រព័ន្ធច្បាប់និងតុលាការឡើងវិញពីបាតដៃទទេ។ រាជរដ្ឋាភិបាលកម្ពុជាបានប្ដេជ្ញាចិត្តខ្ពស់ក្នុងការលើកស្ទួយសិទ្ធិកុមារ តាមរយៈការបង្កើតបរិយាកាសល្អប្រសើរសម្រាប់ការរស់រានមានជីវិតនិងការអភិវឌ្ឍ ការពង្រឹងសុខុមាលភាពកុមារ និងការបង្កើនស្រទាប់បរិយាកាសការពារយ៉ាងរឹងមាំដល់កុមារ។ សកម្មភាពជាច្រើនត្រូវបានអនុវត្តព្រមៗគ្នាមានជាអាទិ៍ ការបង្កើតនិងពង្រឹងក្របខ័ណ្ឌគោលនយោបាយ ច្បាប់ យន្តការ ។ល។ ក្រៅពីក្រសួងនិងស្ថាប័នជំនាញពាក់ព័ន្ធ យន្តការពិសេសជាច្រើនត្រូវបានបង្កើតដើម្បីធានាឱ្យកុមារទទួលបានសិទ្ធិរបស់ខ្លួនយ៉ាងពេញលេញ ដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ ក្រុមការងារថ្នាក់ជាតិពហុវិស័យស្ដីពីកុមារកំព្រានិងកុមារងាយរងគ្រោះ ក្រុមការងារអន្តរក្រសួងដើម្បីយុត្តិធម៌កុមារ ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាលដើម្បីយុត្តិធម៌កុមារ ជាដើម។ យន្តការទាំងនេះ មានចាប់តាំងពីថ្នាក់ជាតិ រាជធានី ខេត្តរហូតដល់ថ្នាក់ឃុំ សង្កាត់ ដែលជាទីកន្លែងកុមាររស់នៅ។

---

[២] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣

## II. កំណែទម្រង់គោលនយោបាយនិងច្បាប់ទាក់ទងនឹងយុត្តិធម៌កុមារ

៤- ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានបង្កើតឡើងក្នុងខែមិថុនា ឆ្នាំ២០០២ មានបេសកកម្មក្នុងការ " ផ្តួចផ្តើមគំនិតនិងជំរុញលើកទឹកចិត្តដល់ដំណើរការកំណែទម្រង់ និងពិនិត្យមើលជាប្រចាំការអនុវត្តគោលនយោបាយនិងកម្មវិធីរបស់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្របទៅតាមទិសដៅនៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ "។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៥មក ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បាននិងកំពុងអនុវត្តផែនការសកម្មភាពរបស់ខ្លួនដើម្បីអនុវត្តតាមយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ផែនការសកម្មភាពនេះបានកំណត់អាទិភាពនិងសកម្មភាពសំខាន់ៗ សម្រាប់អនុវត្តក្នុងរយៈពេលខ្លីទៅមធ្យម (២០០៤-២០០៨) និងរយៈពេលវែង (ក្រោយឆ្នាំ២០០៨)។ យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ មានទិសដៅជាយុទ្ធសាស្ត្រចំនួន ៧ ដូចខាងក្រោម :

- ពង្រឹងការការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋាន
- ធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់
- ផ្តល់លទ្ធភាពទទួលបានព័ត៌មានអំពីច្បាប់និងតុលាការឱ្យបានកាន់តែប្រសើរឡើង
- ធ្វើឱ្យប្រសើរឡើងគុណភាពនៃដំណើរការរឿងក្តីនិងសេវាកម្មពាក់ព័ន្ធ
- ពង្រឹងសេវាកម្មយុត្តិធម៌ រួមមាន អំណាចតុលាការ និងសេវាផ្នែកអយ្យការ
- បង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ
- ពង្រឹងសមត្ថភាពស្ថាប័នវិស័យច្បាប់និងតុលាការ ឱ្យអាចបំពេញអាណត្តិរបស់ខ្លួនបានដោយជោគជ័យ [៣]។

[៣] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ចំណុចទី៣៧

**៥-** កិច្ចការយុត្តិធម៌កុមារស្ថិតនៅក្នុងទិសដៅជាយុទ្ធសាស្ត្រទាំង ៧ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

**៦-** រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ ការដាក់បញ្ចូលអនុសញ្ញាស្តីពីសិទ្ធិកុមារទៅក្នុងរដ្ឋធម្មនុញ្ញ ជាការផ្តល់ឋានៈដល់បទប្បញ្ញត្តិនៃអនុសញ្ញានេះស្មើនឹងឋានៈនៃបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ។ ឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ដោយកំណត់ថាច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ រួមបញ្ចូលជាផ្នែកមួយនៃច្បាប់ជាតិ ដែលចៅក្រមត្រូវផ្អែកលើក្នុងការជំនុំជម្រះក្តី។ នេះជាការបង្កើននិងពង្រឹងបន្ថែមបរិយាកាសការពារដល់កុមារគ្រប់រូប។

**៧-** ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានបង្កើតដោយមានជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ និងត្រូវបានប្រកាសឱ្យប្រើចន្លោះពីឆ្នាំ២០០៧-២០០៩។ ក្រមព្រហ្មទណ្ឌមានបទប្បញ្ញត្តិមួយចំនួនទាក់ទងនឹងកុមារជាអាទិ៍ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌនៃអនីតិជន ទោស

ដែលអាចអនុវត្តចំពោះអនីតិជន ការប៉ះពាល់អនីតិជននិងគ្រួសារ ការប៉ះពាល់ដល់ការថែរក្សាអនីតិជន ការប៉ះពាល់ដល់បុគ្គភាព ការដាក់អនីតិជនឱ្យស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងការជំរុញអនីតិជនប្រព្រឹត្តអំពើល្មើសច្បាប់ឬអំពើគ្រោះថ្នាក់។

**៨-** ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទថ្មីមួយ ដែលមានលក្ខណៈទូលំទូលាយ និងល្អប្រសើរជាងមុន ត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៨។ ច្បាប់នេះមានគោលបំណងបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ដើម្បីថែរក្សា ពង្រឹងប្រពៃណីល្អរបស់ជាតិ ការពារសិទ្ធិសេចក្តីថ្លៃថ្នូររបស់មនុស្ស និងដើម្បីធ្វើឱ្យប្រសើរឡើងសុខភាព និងសុខុមាលភាពរបស់ប្រជាជន និងដើម្បីអនុវត្តឱ្យបានសមស្របផងដែរតាមពិធីសាររបស់អង្គការសហប្រជាជាតិស្តីពីការបង្ការបង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស និងលិខិតូបករណ៍អន្តរជាតិ ឬកិច្ចព្រមព្រៀងដទៃទៀត ទាក់ទងនឹងការជួញដូរមនុស្សដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ឬចូលជាភាគី។ សេចក្តីព្រាងកំណត់ពន្យល់អំពីច្បាប់នេះ ត្រូវបានក្រសួងយុត្តិធមិរៀបរៀងចប់ជាស្ថាពរក្នុងឆ្នាំ២០០៩ ដោយគ្រាន់តែនៅរង់ចាំការដាក់ឱ្យប្រើជាផ្លូវការតែប៉ុណ្ណោះ។

**៩-** ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានចេញសេចក្តីសម្រេចលេខ ១០៧ ក.ជ.ក.ក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងជំរុញការអនុវត្តលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធដែលព្រះរាជាណាចក្រកម្ពុជាបានឱ្យសច្ចាប័នឬចូលជាភាគី និងដើម្បីការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ។ នៅឆ្នាំ២០០៩ ក្រសួងសង្គមកិច្ច

អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) បានដាក់ចេញគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សបានដាក់ឱ្យអនុវត្តតាមប្រកាសលេខ ៨៥២ ស.អ.យ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩។

**១០-** ច្បាប់ស្តីពីសុំកូនអន្តរប្រទេសត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៩ ដើម្បីធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋាន របស់កុមារដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស។ ច្បាប់ស្តីពីការអប់រំត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៧ ដើម្បីធានានិងអនុវត្តន៍សិទ្ធិទទួលបានការអប់រំ ដែលបញ្ញត្តិនៅក្នុងមាត្រា ៦៨ នៃរដ្ឋធម្មនុញ្ញបានចែងថា ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិច ៩ឆ្នាំ។

**១១-** ក្រសួងយុត្តិធម៌បាននិងកំពុងពិនិត្យច្បាប់ និងសេចក្តីព្រាងច្បាប់ជាច្រើនក្នុងនោះរួមទាំងសេចក្តីព្រាងច្បាប់ដែលមានការពាក់ព័ន្ធនឹងកុមារផងដែរ។ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានកែសម្រួលចុងក្រោយដោយក្រុមការងារដែលមានសមាសភាពមកពីក្រសួងចំនួន ៥ ដឹកនាំដោយក្រសួងយុត្តិធម៌។ សេចក្តីព្រាងច្បាប់នេះត្រូវបានបញ្ជូនពីក្រសួងជំនាញទៅទីស្តីការគណៈរដ្ឋមន្ត្រី និងកំពុងដំណើរការពិនិត្យពិភាក្សាដោយក្រុមអ្នកជំនាញនៅទីស្តីការគណៈរដ្ឋមន្ត្រី។ សេចក្តីព្រាងច្បាប់នេះត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមបទដ្ឋានអន្តរជាតិ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមានការចូលរួមផ្តល់យោបល់ពីដៃគូអភិវឌ្ឍន៍ មូលនិធិសហប្រជាជាតិដើម្បីកុមារ និងអង្គការសង្គមស៊ីវិល។ ស្របគ្នានឹងសេចក្តីព្រាងច្បាប់នេះបទបញ្ជា ទម្រង់បញ្ជីត្រួតពិនិត្យ និងឧបករណ៍ផ្សេងៗទៀតសម្រាប់នគរបាល មេធាវីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ ភ្នាក់ងារសង្គមកិច្ច មន្ត្រីពន្ធនាគារ

និងមន្ត្រីស្ពានីតិសម្បទាផ្សេងៗទៀតក៏កំពុងរៀបចំ។ សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីរបៀបចាត់ការចំពោះកុមាររងគ្រោះ និងកុមារជាសាក្សីនៅក្នុងប្រព័ន្ធយុត្តិធម៌កំពុងត្រូវបានពិនិត្យ។ ក្រសួង ស.អ.យ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារកំពុងធ្វើការសិក្សាស្រាវជ្រាវ និងពិនិត្យមើលលទ្ធភាពក្នុងការបង្កើតច្បាប់ស្តីពីការការពារកុមារ ឬច្បាប់ស្តីពីសុខុមាលភាពកុមារ។

**១២-** ក្រៅពីនេះក្រសួងយុត្តិធម៌បានធ្វើសេចក្តីណែនាំស្តីពីការចោទប្រកាន់ ការផ្តន្ទាទោសជនប្រព្រឹត្តបទល្មើសជួញដូរមនុស្សនិងធ្វើអាជីវកម្មផ្លូវភេទ និងបានចេញសេចក្តីណែនាំអំពីការអនុវត្តគោលការណ៍ច្បាប់ជាតិនិងអន្តរជាតិ ដែលនៅជាធរមានទាក់ទងទៅនឹងកិច្ចការពារជនរងគ្រោះពីបទល្មើសព្រហ្មទណ្ឌ និងសេចក្តីណែនាំអំពីការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅជាធរមានទាក់ទងទៅនឹងយុត្តិធម៌អនីតិជន។ បន្ថែមលើនេះទៀត ក្រសួងយុត្តិធម៌បានចេញប្រកាសស្តីពីការប្រើរបាំងក្នុងបន្ទប់សវនាការ និងបន្ទប់សវនាការភ្ជាប់បណ្តាញទូរទស្សន៍ដើម្បីយកសក្ខីកម្មពីកុមារ ឬជនរងគ្រោះ ឬសាក្សី ដែលងាយរងគ្រោះ។

**១៣-** គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ និងបទដ្ឋានផ្សេងៗទៀតទាក់ទងនឹងការថែទាំជំនួសត្រូវបានដាក់ឱ្យប្រើប្រាស់ដោយក្រសួង ស.អ.យ។ ក្រសួង ស.អ.យ បានចេញប្រកាសស្តីពីការទទួលស្គាល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស និងបទដ្ឋានផ្សេងទៀតដើម្បីធានាអនុវត្តច្បាប់ស្តីពីសុំកូនអន្តរប្រទេស ជាពិសេស គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឱ្យមានប្រសិទ្ធភាពដំណាលគ្នានឹងការជំរុញកិច្ចការពារផ្នែកសង្គមដល់កុមារ។

**១៤-** ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ត្រូវបានប្រកាសឱ្យប្រើតាំងពីឆ្នាំ២០០៥។ ច្បាប់នេះផ្ដល់យន្តការផ្លូវច្បាប់ដើម្បីបង្ការអំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះដោយបន្ថែមទៅលើបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន។

**១៥-** ដើម្បីធានាសិទ្ធិសុខភាពរបស់កុមារ ក្រសួងសុខាភិបាលកំពុងរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីការត្រួតពិនិត្យថ្នាំជក់ ដែលក្នុងនោះបញ្ញត្តិហាមលក់បារីឱ្យកុមារក្រោមអាយុ ១៨ឆ្នាំ ។

**១៦-** នៅឆ្នាំ២០០៦ ក្រសួង ស.អ.យ បានចេញប្រកាសស្ដីពីលក្ខខណ្ឌ និងនីតិវិធីនៃការទទួលការគ្រប់គ្រង និងការស្តារនីតិសម្បទាកុមារ។ ប្រកាសអន្តរក្រសួងត្រូវបានធ្វើឡើងដោយក្រសួង ស.អ.យ និងក្រសួងមហាផ្ទៃនៅឆ្នាំ២០០១ ស្ដីពីការអប់រំកែប្រែ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់ទណ្ឌិត។ នៅឆ្នាំ២០០៣ ក្រសួងមហាផ្ទៃបានចេញនីតិវិធីលេខ ៣៤ ស្ដីពីកូនរបស់អ្នកទោសស្ត្រី និងអ្នកទោសស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារក្នុងគោលបំណងគ្រប់គ្រង និងថែទាំអ្នកទោសស្ត្រីដែលមានផ្ទៃពោះ និងកូនអ្នកទោសស្ត្រីនៅក្នុងពន្ធនាគារ។

**១៧-** អនុក្រឹត្យលេខ ១០៣ ស្ដីពីអត្រានុកូលដ្ឋានស៊ីវិលត្រូវបានបង្កើតនៅឆ្នាំ២០០០ ដោយតម្រូវឱ្យឪពុកឬម្ដាយរាយការណ៍ អំពីកំណើតរបស់ទារកក្នុងរយៈពេល ៣០ថ្ងៃ ដល់មន្ត្រីអាត្រានុកូលដ្ឋាននៅសាលាឃុំ ឬសង្កាត់ នៃលំនៅឋានអចិន្ត្រៃយ៍របស់ឪពុកឬម្ដាយ។ ក្រសួងមហាផ្ទៃបានចេញសេចក្ដីណែនាំលេខ ០៤៩ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ ស្ដីពីយុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័តទូទាំងប្រទេស។ ជាលទ្ធផល

ភាគរយនៃប្រជាជនដែលមានសំបុត្រកំណើតបានកើនពី ២២% ក្នុងឆ្នាំ២០០០ ដល់ ៨៩% ក្នុងឆ្នាំ២០០៦។ នៅឆ្នាំបន្តបន្ទាប់មកទៀតការកើនឡើងចំនួនកុមារចុះសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតនៅមានកម្រិត។ ទោះបីជានៅពេលនេះទិន្នន័យដោយឡែកតាមអាយុនិងភេទមិនទាន់មាននៅឡើយ ក្រសួងមហាផ្ទៃបានណែនាំអភិបាលរាជធានី ខេត្ត ឱ្យប្រមូលទិន្នន័យប្រជាពលរដ្ឋអាយុក្រោម ១៨ឆ្នាំ ដែលបានចុះបញ្ជីកំណើត[៤]។ មាត្រា ៩៨៥ នៃក្រមរដ្ឋប្បវេណីបញ្ញត្តិអំពីករណីយកិច្ចនៃការសុំចុះកំណើតថា " ឪពុកឬម្តាយរបស់កូន ត្រូវសុំចុះកំណើតរបស់កូននៅសាលាឃុំសង្កាត់នៃលំនៅឋានរបស់ឪពុកឬម្តាយក្នុងអំឡុងពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលកូននោះកើត "។ ក្នុងករណីដែលឪពុកម្តាយបានធ្វេសប្រហែសនឹងករណីយកិច្ច ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ដោយគ្មានមូលហេតុត្រឹមត្រូវនឹងត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១០.០០០ (មួយម៉ឺនរៀល) ។

**១៨-** ក្នុងចន្លោះឆ្នាំ២០០០-២០១០ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ ហើយក្រសួងទេសចរណ៍បានចេញសារាចរដើម្បីទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ដោយផ្តោតលើផ្នែកទេសចរណ៍មានដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាននិងរង្គសាល និងធ្វើការត្រួតពិនិត្យខ្សែភាពយន្តនិងវីដេអូ។ នៅឆ្នាំ២០០៩ ច្បាប់ស្តីពីទេសចរណ៍ត្រូវបានប្រកាសឱ្យប្រើក្នុងគោលដៅកំណត់វិធាននិងយន្តការសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យទេសចរណ៍ ដោយបញ្ញត្តិហាមធ្វើសកម្មភាពពាក់ព័ន្ធដល់ការជួញដូរកុមារ និងការធ្វើសកម្មភាពផ្លូវភេទផ្សេងទៀត។

---

[៤] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ លេខ ៤៩៥ ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៦

**១៩-** ទន្ទឹមនឹងការអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ព្រះរាជាណាចក្រកម្ពុជាបានចាត់វិធានការប្រកបដោយការទទួលខុសត្រូវ ដើម្បីទទួលស្គាល់ និងធានាសិទ្ធិទាំងអស់របស់កុមារគ្រប់រូប តាមរយៈការផ្តល់សច្ចាប័ន និងការចូលជាភាគីសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងកុមារមានដូចជា ÷

- អនុសញ្ញាស្តីពីសិទ្ធិកុមារ នៅឆ្នាំ១៩៩២
- ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ នៅឆ្នាំ២០០២
- ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការជួញដូរកុមារការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារនៅឆ្នាំ២០០២
- អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ នៅឆ្នាំ២០០៦
- ពិធីសារប៉ាលែម៉ូស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង នៅឆ្នាំ២០០៦
- អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងកិច្ចសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសនៅឆ្នាំ២០០៧
- ពិធីសាររបស់អង្គការសហប្រជាជាតិ ដើម្បីបង្ការ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស នៅឆ្នាំ២០០១

- អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្មនិងការផ្តន្ទាទោស ឬការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្សនៅឆ្នាំ១៩៩២
- អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅឆ្នាំ១៩៩២
- កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅឆ្នាំ១៩៩២
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៅឆ្នាំ១៩៩២
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍នៅឆ្នាំ១៩៨៣
- អនុសញ្ញាលេខ ២៩ ស្តីពីការងារដោយបង្ខំ និងជាកាតព្វកិច្ចនៅឆ្នាំ១៩៧០
- អនុសញ្ញាបន្ថែមរបស់អង្គការសហប្រជាជាតិស្តីពីការលុបចោលទាសភាព ការជួញដូរទាសករ និងការអនុវត្ត ស្រដៀងគ្នានឹងទាសភាពនៅឆ្នាំ១៩៥៧
- អនុសញ្ញាស្តីពីការទទួលបានព័ត៌មាន ការចូលរួមជាសាធារណៈក្នុងការធ្វើសេចក្តីសម្រេច ហើយការទទួលបានភាពយុត្តិធម៌ក្នុងបញ្ហាបរិស្ថាននៅឆ្នាំ១៩៩៨។

**២០-** គោលការណ៍ណែនាំ បទដ្ឋាន និងគោលការណ៍ច្បាប់អន្តរជាតិសំខាន់ៗទាក់ទងនឹងយុត្តិធម៌កុមារ ដូចជាគោលការណ៍ទាក់ទងនឹងការទទួលខុសត្រូវរបស់អនីតិជន គោលការណ៍ទាក់ទងនឹងការបង្វែរចេញពីប្រព័ន្ធយុត្តិធម៌ ដែលមានចែងក្នុងវិធានជាបទដ្ឋានអប្បបរមាសម្រាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន គោលការណ៍ណែនាំនៃអង្គការសហប្រជាជាតិសម្រាប់បង្ការ អនីតិជនប្រព្រឹត្តបទល្មើស និងវិធានរបស់អង្គការ

សហប្រជាជាតិសម្រាប់ការពារអនីតិជនដែលត្រូវដកហូតសេរីភាព គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីយុត្តិធម៌ចំពោះបញ្ហាទាក់ទងនឹងកុមារជាជនរងគ្រោះ និងជាសាក្សីនៃបទល្មើសព្រហ្មទណ្ឌ និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីចំណាត់ការចំពោះកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ពាក់ព័ន្ធ ជាពិសេសសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងក្នុងកម្មវិធីសិក្សារបស់អ្នកជំនាញ ដូចជា ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីជាដើម ។

**២១-** ក្រុមការងារចម្រុះស្តីពីយុត្តិធម៌កុមារ ដែលមានសមាសភាពមកពីក្រសួងចំនួន ៥ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានបង្កើតដើម្បីរៀបចំពិភាក្សា និងបង្កើនល្បឿនការធ្វើសេចក្តីព្រាងច្បាប់ និងបទបញ្ញាទាក់ទងនឹងវិស័យយុត្តិធម៌កុមារ ។ ក្រុមការងារនេះបានដាក់ចេញផែនការសកម្មភាពឆ្នាំ២០១០-២០១១ ដើម្បីជំរុញឱ្យសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានអនុម័តដោយសភាជាតិនៅឆ្នាំ២០១១ ផ្តួចផ្តើមគំនិតក្នុងការអនុវត្តគម្រោងសាកល្បងមួយនៅឆ្នាំ២០១១ ស្តីពីតុលាការកុមារ ឬសភាកុមារ និងពង្រឹងសមត្ថភាពដល់តួអង្គយុត្តិធម៌ព្រហ្មទណ្ឌ ក្រុមការងារចម្រុះអង្គការសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធ នៅគ្រប់កម្រិតឱ្យមានការយល់ដឹងពីអនុសញ្ញាស្តីពីសិទ្ធិកុមារនិងប្រព័ន្ធយុត្តិធម៌អនីតិជន ។

## III. កំណែទម្រង់តុលាការ

**២២-** យោងតាមសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចំពោះមុខនៅតាមតុលាការនីមួយៗអាចនឹងបង្កើតឱ្យមានសភាអនីតិជន ។

**២៣-** ក្រសួងយុត្តិធម៌បានដាក់ឱ្យប្រើប្រាស់សាកល្បងបញ្ជីចុះរឿងក្តីអនីតិជននៅក្នុងតុលាការមួយនៃព្រះរាជាណាចក្រកម្ពុជា ។

## IV. នីតិវិធីកុមារមេត្រីនិងតុលាការកុមារមេត្រី

**២៤-** បទដ្ឋាន លក្ខណវិនិច្ឆ័យ និងយុទ្ធសាស្ត្រសម្រាប់តុលាការគំរូត្រូវបានរៀបចំឡើងដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ក្រសួងយុត្តិធម៌បាន និងកំពុងរៀបចំផែនការសកម្មភាពរួមនិងសៀវភៅបញ្ជីដំណើរការរឿងក្តីនានា ដើម្បីអនុវត្តសាកល្បងបង្កើតតុលាការគំរូចំនួន ៤ ដាក់ឱ្យដំណើរការ។ ផែនការសកម្មភាពត្រូវបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីស្នើសុំថវិកា។ ក្រសួងយុត្តិធម៌បានបំពាក់របាំងក្នុងបន្ទប់សវនាការនៅក្នុងសាលាដំបូងរាជធានី ខេត្តទូទាំងប្រទេស។ បន្ទប់សវនាការភ្ជាប់បណ្តាញទូរទស្សន៍ ដើម្បីយកសក្ខីកម្មពីកុមារឬជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះត្រូវបានបំពាក់នៅក្នុងសាលាដំបូងរាជធានី ខេត្តចំនួន ៥។ ជាមួយគ្នានេះដែរក្រសួងបានផលិតវីដេអូសម្រាប់អប់រំណែនាំកុមាររងគ្រោះ កុមារជាសាក្សី និងកុមារល្មើសនឹងច្បាប់ស្តីពីតួនាទីរបស់តួអង្គយុត្តិធម៌ព្រហ្មទណ្ឌ។ ដោយឡែក ក្រសួងមហាផ្ទៃបានប្រើប្រាស់បន្ទប់សម្ភាសន៍អនីតិជនរងគ្រោះ ដែលមានបំពាក់ឧបករណ៍បច្ចេកទេសត្រឹមត្រូវនៅតាមនាយកដ្ឋានជំនាញ ក៏ដូចជានៅតាមរាជធានី ខេត្តសំខាន់ៗមួយចំនួន។

**២៥-** សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមបទដ្ឋានអន្តរជាតិ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមានការគិតគូរដល់ភាពរសើបនៃបញ្ហាកុមារ និងតម្រូវឱ្យដឹកនាំនីតិវិធីប្រកបដោយលក្ខណៈកុមារមេត្រី។

## V. ការអង្កេតស្រាវជ្រាវទាក់ទងនឹងកុមារ

**២៦-** ការប៉ាន់ប្រមាណអំពីស្ថានភាពកុមារល្មើសនឹងច្បាប់នៅព្រះរាជាណាចក្រកម្ពុជា បានប្រព្រឹត្តទៅចាប់ពីខែមីនា ដល់ ខែសីហា ឆ្នាំ២០០៤ ដើម្បីពិនិត្យមើលអំពីទង្វើមកលើកុមារល្មើសនឹងច្បាប់នៅកម្ពុជា ហើយត្រូវបានធ្វើការផ្សព្វផ្សាយដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ការប៉ាន់ប្រមាណនេះបានស្នើឡើងអនុសាសន៍ដែលជាចំណុចអាទិភាពចំនួន ១០ ដើម្បីធ្វើការកែទម្រង់ដែលក្នុងនោះរួមមាន : កំណែទម្រង់ច្បាប់ព្រហ្មទណ្ឌទូទៅ កំណែទម្រង់ច្បាប់នីតិវិធីព្រហ្មទណ្ឌនិងភស្តុតាង ការឃុំខ្លួនបណ្តោះអាសន្ននិងកិច្ចធានាការប្រព្រឹត្តរបស់នគរបាលយុត្តិធម៌មកលើកុមារ ការការពារតាមផ្លូវច្បាប់ ការផ្តន្ទាទោសកុមារ ការដោះលែងនិងការដោះលែងដោយមានលក្ខខណ្ឌ កំណែទម្រង់ច្បាប់ទាក់ទងនឹងយុត្តិធម៌អនីតិជន ការបង្វែរ និងការអភិវឌ្ឍសូចនាករគន្លឹះថ្នាក់ជាតិ។

## VI. ការពង្រឹងសមត្ថភាពស្ថាប័ននិងអ្នកអនុវត្តច្បាប់

**២៧-** ចាប់តាំងពីឆ្នាំ២០០៦មក វគ្គបណ្តុះបណ្តាលមូលដ្ឋានស្តីពីសិទ្ធិកុមារ ច្បាប់ និងយុត្តិធម៌ត្រូវបានបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការសម្រាប់បណ្តុះបណ្តាលដល់ចៅក្រម និងព្រះរាជអាជ្ញាកំពុងបម្រើការ។ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បានផលិតវីដេអូបណ្តុះបណ្តាល ២ សម្រាប់មន្ត្រីតុលាការសម្ភាសន៍កុមាររងគ្រោះ និងកុមារប្រព្រឹត្តល្មើសនឹងច្បាប់។

**២៨-** ចាប់តាំងពីឆ្នាំ២០០៦មក វគ្គបណ្តុះបណ្តាលមូលដ្ឋានស្តីពីសិទ្ធិកុមារ ច្បាប់ និងយុត្តិធម៌ត្រូវបានបញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលរបស់សាលាមេធាវីសម្រាប់បណ្តុះបណ្តាលដល់សិស្សមេធាវី ។

**២៩-** ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងយុត្តិធម៌បានរៀបចំឱ្យមានការបណ្តុះបណ្តាលរួមគ្នា និងការបណ្តុះបណ្តាលដោយឡែកសម្រាប់នគរបាលយុត្តិធម៌ វេជ្ជបណ្ឌិត និងតុលាការស្តីអំពីនីតិវេជ្ជសាស្ត្រ និងការស៊ើបអង្កេតករណីរំលោភបំពានផ្លូវភេទលើកុមារ។ វគ្គបណ្តុះបណ្តាលទី១ស្តីពី " ទិដ្ឋភាពនីតិវេជ្ជសាស្ត្រ និងទិដ្ឋភាពសុខុមាលភាពនៃការស៊ើបអង្កេតករណីរំលោភបំពានផ្លូវភេទលើកុមារ " ប្រព្រឹត្តទៅនៅខែតុលា ឆ្នាំ២០០៨។ វគ្គបណ្តុះបណ្តាលបន្តស្តីពី " ទិដ្ឋភាពនីតិវេជ្ជសាស្ត្រ និងទិដ្ឋភាពច្បាប់នៃការស៊ើបអង្កេតករណីរំលោភបំពានផ្លូវភេទលើកុមារប្រព្រឹត្តទៅនៅខែមករា ឆ្នាំ២០១០។

**៣០-** នៅឆ្នាំ២០០៩ នគរបាលយុត្តិធម៌នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងមន្ត្រីនៃការិយាល័យប្រឆាំងការជួញដូរនិងការពារអនីតិជននៃរាជធានី ខេត្តចំនួន ១០ បានទទួលការហ្វឹកហ្វឺននៅនឹងកន្លែងស្តីអំពីការតាមដានករណី ការគ្រប់គ្រងករណីនៅក្នុងពេលស៊ើបអង្កេត និងការបញ្ជូនករណីជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ។ សៀវភៅបណ្តុះបណ្តាលនគរបាលត្រូវបានធ្វើបច្ចុប្បន្នកម្មដោយដាក់បញ្ចូលបទប្បញ្ញត្តិពាក់ព័ន្ធ ដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ សិក្ខាសាលាថ្នាក់ជាតិចំនួន ២លើក ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីការិយាល័យ និងផ្នែកប្រឆាំងការជួញដូរនិងការពារអនីតិជននៃរាជធានី ខេត្តទាំង ២៤ ដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍ និងមេរៀនល្អក្នុងការចាត់ការករណីរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ និងអំពើហិង្សាលើកុមារ និងស្ត្រី និងពិនិត្យឡើងវិញទិដ្ឋភាពច្បាប់និងបច្ចេកទេសស៊ើបអង្កេត។ អធិការ អធិការរង ប្រធានប៉ុស្តិ៍រដ្ឋបាល និងអនុប្រធានប៉ុស្តិ៍រដ្ឋបាលចំនួន ៩៥០នាក់នៃរាជធានី ខេត្តចំនួន ១០

បានទទួលការបណ្តុះបណ្តាលស៊ីជម្រៅទាក់ទងនឹងនីតិវិធីច្បាប់ ជំនាញស៊ើបអង្កេត និងការសហការជាមួយអាជ្ញាធរមូលដ្ឋាន។ នគរបាលយុត្តិធម៌ជាង ១៧០០នាក់ បានទទួលការបណ្តុះបណ្តាលនៅបណ្ឌិតសភានគរបាល និងសាលាហ្វឹកហ្វឺននគរបាលនៅតាមភូមិភាគចំនួន ៥ ដើម្បីធ្វើឱ្យជ្រួតជ្រាបអំពីបញ្ហាទាក់ទងនឹងការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ ការជួញដូរកុមារ និងនីតិវិធីក្នុងការចាត់ការករណីទាំងនោះ។

**៣១-** នៅព្រះរាជាណាចក្រកម្ពុជាទើបតែមានដេប៉ាតឺម៉ង់សង្គមកិច្ចវិទ្យា នៃសកលវិទ្យាល័យភ្នំពេញ។ គិតមកទល់ឆ្នាំ២០០៩ ចំនួន ៥៤% នៃមន្ត្រីសង្គមកិច្ចថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និង ៨៣% នៃមន្ត្រីសង្គមកិច្ចថ្នាក់ស្រុកបានទទួលវគ្គបណ្តុះបណ្តាលមូលដ្ឋាន និងជំនាញស្តីពីកិច្ចការសង្គម។ មេរៀនស្តីអំពីតួនាទីមន្ត្រីសង្គមកិច្ចនៅក្នុងប្រព័ន្ធយុត្តិធម៌កុមារត្រូវបានដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលមូលដ្ឋាន និងថ្នាក់ជំនាញខាងសេវាសង្គមកិច្ចនៃក្រសួង ស.អ.យ។

**៣២-** ក្នុងឆ្នាំ២០០៩ មន្ត្រីសង្គមកិច្ច មន្ត្រីពន្ធនាគារ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមកពីរាជធានី ខេត្ត ចំនួន ៧ បានទទួលការបំពាក់បំប៉នជំនាញតាមរយៈការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងករណី និងការធ្វើផែនការសមាហរណកម្មកុមារប្រព្រឹត្តល្មើសនឹងច្បាប់។ ក្រសួងយុត្តិធម៌បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលពហុវិស័យស្តីពីយុត្តិធម៌កុមារសម្រាប់គ្រូបង្គោលចំនួន ៣៩នាក់ ដែលជាមន្ត្រីតុលាការ សង្គមកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល។

## VII. សេវានិងជំនួយ

**៣៣-** បទល្មើសផ្លូវភេទក្នុងឆ្នាំ២០០៩ ជាបទល្មើសដែលមានចំនួនច្រើនប្រៀបធៀបនឹងបទល្មើសផ្សេងទៀតដូចជា : អំពើហិង្សាក្នុងគ្រួសារ ការកេងប្រវ័ញ្ចផ្លូវភេទ និង

រូបភាពអាសអាភាស និងការជួញដូរមនុស្ស។ បទល្មើសទាំងនេះ នាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជនបានធ្វើការស៊ើបអង្កេត។ មានអង្គភាពជំនាញជាច្រើនដែលបាននិងកំពុងធ្វើសកម្មភាពបង្ការ ទប់ស្កាត់ និងបង្ក្រាបការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ រូបភាពនិងសម្ភារៈអាសអាភាស អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ ដូចជាអង្គភាពនៃក្រសួងមហាផ្ទៃ និងអង្គភាពជំនាញនៃក្រសួងការពារជាតិ។

តារាងខាងក្រោមរបស់ក្រសួងមហាផ្ទៃ បង្ហាញឱ្យឃើញពីសមិទ្ធផលដូចតទៅ :

| **បទល្មើស** | **ចំនួនករណីដែលបានបង្ក្រាប** | **ចំនួនជនរងគ្រោះដែលបានសង្គ្រោះ** | **ចំនួនជនជាប់សង្ស័យដែលបានចាប់ខ្លួន** |
|---|---|---|---|
| **ការរំលោភបំពានផ្លូវភេទ** | | | |
| -រំលោភសេពសន្ថវៈ | ១៨៥ | | ២១៣ |
| -អំពើបៀតបៀនកេរ្តិ៍ខ្មាស | ១៨ | | ១៨ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១៨ | ១០ |
| **ការកេងប្រវ័ញ្ចផ្លូវភេទ** | ៨៨ | ៨១៥ | ៥៧ |
| **រូបភាពនិងសម្ភារៈអាសអាភាស** | ២១ | | ១៥ |
| **ការបង្ខាំង** | ០១ | ០១ | |
| **ការកេងប្រវ័ញ្ចពលកម្ម** | | | |
| **អំពើជួញដូរមនុស្ស** | ៨៨ | ១៨០ | ៥១ |
| **អំពើហិង្សាក្នុងគ្រួសារ** | ៨៨ | ១៥៩ | ៨៨ |
| **សរុប** | **៤៥៦** | **៧៧៣** | **៤៥២** |

**៣៤-** ក្រសួង ស.អ.យ ផ្តល់សេវាបញ្ជូន និងសមាហរណកម្មកុមារ និងស្រ្តីរងគ្រោះ និងងាយរងគ្រោះដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ។ ក្នុងឆ្នាំ២០០៩ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជួញដូរកម្លាំងពលកម្មចំនួន ៩៩២នាក់ ដែលធ្វើមាតុភូមិនិវត្តន៍មកពីប្រទេសថៃចំនួន ២១៥នាក់ មកពីប្រទេសវៀតណាម ៧៧៣នាក់ និងមកពីប្រទេសម៉ាឡេស៊ី ៤នាក់ ក្នុងនោះកុមារ ៥១៥នាក់ ត្រូវបានស្តារនីតិសម្បទា និងធ្វើសមាហរណកម្ម។ នារី និងកុមារីរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទក្នុងប្រទេសចំនួន ៤៦៩នាក់ ត្រូវបានសង្គ្រោះ និងផ្តល់សេវាសមស្របនៅមជ្ឈមណ្ឌលរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល ហើយជនរងគ្រោះចំនួន ១.៤៧៤នាក់ ត្រូវបានធ្វើសមាហរណកម្ម និងបិទករណី ៥១៦នាក់ ។

**៣៥-** ក្រសួង ស.អ.យ ផ្តល់សេវាគ្រប់គ្រងករណី ស្តារនីតិសម្បទា និងសមាហរណកម្ម ដល់កុមារល្មើសនឹងច្បាប់ដែលជាប់ក្នុងពន្ធនាគារចំនួន ៤ និងកុមារដែលប្រព្រឹត្តបទលហុ ឬប្រើសារធាតុញៀនដែលត្រូវបានបង្វែរចេញពីពន្ធនាគារទៅស្តារនីតិសម្បទា។ កុមារចំនួន ៩០% (៧០៥នាក់) នៃកុមារទាំងអស់ដែលជាប់ពន្ធនាគារ និងមណ្ឌលស្តារនីតិសម្បទាបានទទួលផលពីសេវាសង្គមកិច្ច ដូចជាសេវាគ្រប់គ្រងករណី ការពិគ្រោះយោបល់ ការអប់រំក្រៅប្រព័ន្ធ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្វែងរកគ្រួសារ ការតាមដាន និងការថែទាំក្រោយមកទៀត។ កុមារប្រហែល ៧០% នៃកុមារដែលត្រូវបានដោះលែងពីពន្ធនាគារ និងកុមារដែលទទួលការស្តារនីតិសម្បទា បានធ្វើសមាហរណកម្មប្រកបដោយជោគជ័យ។ មន្រ្តីសង្គមកិច្ចនៃមន្ទីរ ស.អ.យ ខេត្តបាត់ដំបងនិងខេត្តសៀមរាប ធ្វើសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរក្នុងការផ្តល់ជំនាញបំណិន

ជីវិត ការធ្វើផែនការសមាហរណកម្ម ការតាមដានក្រោយពេលដោះលែងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាផ្សេងទៀតនៅតាមសហគមន៍ដល់កុមារក្នុងខេត្តទាំងពីរ ។

**៣៦-** រាជរដ្ឋាភិបាលបានបង្កើនរបបហូបចុកប្រចាំថ្ងៃសម្រាប់ទណ្ឌិត និងពិរុទ្ធជនម្នាក់ដល់ ២៨០០រៀលក្នុងមួយថ្ងៃ ។

**៣៧-** ក្នុងចន្លោះខែតុលា ឆ្នាំ២០០៨ ដល់ខែតុលា ឆ្នាំ២០០៩ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានជួយការពារក្តីជូនជនក្រីក្រចំនួន ៥៤៤ករណី ក្នុងនោះមានអនីតិជន ៦៦នាក់ និងស្ត្រី ៤៥នាក់[៥] ។ ក្រៅពីនេះ សេវាផ្នែកច្បាប់លើសលុបត្រូវបានផ្តល់ឱ្យកុមារតាមរយៈអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាផ្នែកច្បាប់ ។

**៣៨-** ចំពោះសេចក្តីលំអិតសមិទ្ធផលដែលព្រះរាជាណាចក្រកម្ពុជាសម្រេចបាន សូមមើលរបាយការណ៍លើកទី ២ និងទី ៣ របស់កម្ពុជាស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ឆ្នាំ២០០០ ដល់២០០៧ ដែលភ្ជាប់ជូនមកជាមួយជាឧបសម្ព័ន្ធ ។

## VIII. ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ការបង្ការ និងការបង្វែរ

**៣៩-** ចាប់តាំងពីឆ្នាំ២០០៨ មកក្នុងខេត្តចំនួន ៤ នៃព្រះរាជាណាចក្រកម្ពុជាមានការអនុវត្តកម្មវិធីតាមសហគមន៍ដើម្បីបង្ការ និងស្តារនីតិសម្បទាអនីតិជនដែលប្រព្រឹត្តបទល្មើសលហុ តាមរយៈសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន២ ។ កម្មវិធីនេះសហការជាមួយអាជ្ញាធរឃុំក្នុងការបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារ បំណិនជីវិត និងការ

---

[៥] របាយការណ៍ស្តីពីសកម្មភាពរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ខែតុលា ឆ្នាំ២០០៨- ខែតុលា ឆ្នាំ២០០៩

គ្រប់គ្រងកំហឹងជាដើមដល់កុមារស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ជាង ១០០នាក់ ព្រមទាំងតាមដានការបង្វែរអនីតិជនចេញពីប្រព័ន្ធតុលាការ និងជម្រើសនានាសម្រាប់កុមារល្មើសនឹងច្បាប់ចំនួន ៣១នាក់ ក្នុងឆ្នាំ២០០៩។ កម្មវិធីនេះធ្វើសហប្រតិបត្តិការជាមួយមន្ទីរសង្គមកិច្ចខេត្តពាក់ព័ន្ធក្នុងការផ្តល់ជំនាញបំណិនជីវិត ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្តល់ជំនួយសម្ភារៈ ការបញ្ជូនទៅសេវាសុខភាព និងការចុះពិនិត្យតាមដាន។ លើសពីនេះទៀត កម្មវិធីបានជួយអាជ្ញាធរឃុំឱ្យមានការជួបប្រជុំពីរខែម្តងជាមួយឪពុក ម្តាយ អ្នកស្ម័គ្រចិត្តនៅតាមសហគមន៍ និងប្រជាពលរដ្ឋនៅតាមសហគមន៍ស្តីពីសិទ្ធិកុមារ បញ្ហាច្បាប់ បញ្ហាសង្គម ការបង្ការអំពើហិង្សា និងការបង្ការ មិនឱ្យអនីតិជនប្រព្រឹត្តបទល្មើស។ ដើម្បីធានានិរន្តរភាពកម្មវិធីស្តីពីការធ្វើអន្តរាគមន៍ និងការបង្ការនេះកំពុងត្រូវបានរៀបចំដាក់បញ្ចូលក្នុងផែនការវិនិយោគនិងអភិវឌ្ឍន៍របស់ឃុំ។

**៤០-** នៅក្នុងខេត្តមួយផ្សេងទៀតមានកម្មវិធីសាកល្បងមួយហៅថា កម្មវិធីបង្ការបទល្មើសព្រហ្មទណ្ឌត្រូវបានអនុវត្ត ដើម្បីបញ្ចៀសយុវជននៅក្នុងសហគមន៍មិនឱ្យប្រព្រឹត្តបទល្មើសតាមរយៈសកម្មភាពនានាដូចជាការបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអាទិ៍ ត្រូវបានអនុវត្តន៍សាកល្បងដោយក្រសួងមហាផ្ទៃនៅក្នុងឃុំចំនួន ៤៥ ក្នុងស្រុកចំនួន ១១។

**៤១-** ក្រសួង ស.អ.យ បានបង្កើត និងធ្វើតេស្តសាកល្បងបទបញ្ជារបស់ក្រសួងនិងយន្តការស្តីពីការប្រព្រឹត្តទៅនៃប្រព័ន្ធសុខុមាលភាពកុមារក្នុងខេត្តចំនួន ៥។ យន្តការនៅថ្នាក់មូលដ្ឋានកំពុងត្រូវបានធ្វើតេស្តសាកល្បងក្នុងគោលបំណងកំណត់គ្រួសារ និងកុមារងាយរងគ្រោះ ផ្តល់ការជួយឧបត្ថម្ភគាំទ្រដល់គ្រួសារនិងផ្តល់សេវាបញ្ជូនដើម្បីបង្ការការបែកបាក់គ្រួសារ ឬការមិនអាចធ្វើសមាហរណកម្ម លើកទឹកចិត្តការបង្រួប

បង្រួមកុមារជាមួយនឹងគ្រួសារ និងស្វែងរកដំណោះស្រាយនៅតាមសហគមន៍ជូនកុមាររងគ្រោះ ។

## IX. ការលើកកម្ពស់ការយល់ដឹង

**៤២-** ការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ទាក់ទងនឹងយុត្តិធម៌កុមារធ្វើឡើងតាមរយៈការបោះពុម្ពផ្សាយច្បាប់ និងកំណត់ពន្យល់រួមមានក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ អនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែមនៃអនុសញ្ញានិងច្បាប់ផ្សេងៗទៀត ។

**៤៣-** ការលើកកម្ពស់ការយល់ដឹងក្នុងចំណោមយុវជន និងកុមារធ្វើឡើងតាមរយៈកម្មវិធីជំនួយផ្នែកច្បាប់ ការផ្សព្វផ្សាយអំពីសិទ្ធិកុមារ និងសិទ្ធិផ្នែកនីតិវិធីនៅតាមពន្ធនាគារតាមរយៈកម្មវិធីបង្ការបទល្មើស និងកម្មវិធីបង្វែរជាដើម ។ ការផ្សព្វផ្សាយលើសលប់ ធ្វើទៅលើប្រធានបទទាក់ទងនឹងបទល្មើសផ្លូវភេទលើកុមារនិងស្ត្រីរងគ្រោះតាមរូបភាពដូចជារឿងខ្លីៗ ឈុតឆាកខ្លីៗ ការពិភាក្សាតាមវិទ្យុនិងទូរទស្សន៍ អ៊ីនធឺណិតតាមរយៈប័ណ្ណផ្ទត់ ខិតប័ណ្ណ សិក្ខាសាលា និងការបណ្តុះបណ្តាល ។

**៤៤-** ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ និងមេភូមិស្ត្រីនៅក្នុងខេត្តអាទិភាពត្រូវបានបណ្តុះបណ្តាលអំពីរបៀបតស៊ូមតិ ធ្វើផែនការនិងអនុវត្តន៍សកម្មភាពលើកស្ទួយនិងធ្វើឱ្យសម្រេចបានសិទ្ធិស្ត្រីនិងកុមារ ។

## X. ការបង្កើតប្រព័ន្ធទិន្នន័យនិងការគ្រប់គ្រងព័ត៌មាន

**៤៥-** ព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពីស្ថិតិដែលគ្រប់គ្រងលើផ្នែកទាំងអស់ទាក់ទងនឹងការប្រមូល ដំណើរការនៃការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យ។ កន្លងមកប្រព័ន្ធទិន្នន័យកម្ពុជា (CAMInfo) បានកែសម្រួលពី DevInfo ដែលត្រូវបានវិទ្យាស្ថានជាតិស្ថិតិប្រកាសដាក់ឱ្យប្រើប្រាស់នៅខែមីនា ឆ្នាំ ២០០៤។ CAMInfo ត្រូវបានទទួលស្គាល់ថា ជាមូលដ្ឋានទិន្នន័យសូចនាករជាតិស្តីពីសេដ្ឋកិច្ច សង្គមកិច្ច សម្រាប់ការតាមដានភាពរីកចម្រើនធៀបនឹងគោលដៅអភិវឌ្ឍន៍ និងគោលដៅផ្សេងៗទៀតរបស់ជាតិ គោលដៅតំបន់ និងពិភពលោក។ CAMInfo រួមមានទិន្នន័យថ្នាក់ជាតិរហូតដល់ឃុំ ដែលអាចធ្វើឱ្យមានការតាមដានពីសូចនាករនានានៅថ្នាក់មូលដ្ឋាន។

**៤៦-** នៅឆ្នាំ១៩៩៩ ក្រសួង ស.អ.យ បានបង្កើតប្រព័ន្ធទិន្នន័យដើម្បីប្រមូលផ្តុំព័ត៌មានអំពីការបញ្ជូនត្រឡប់មកវិញស្ត្រីនិងកុមាររងគ្រោះ និងងាយរងគ្រោះដោយសារការជួញដូរដែលបញ្ជូនត្រឡប់មកពីប្រទេសនានា។

**៤៧-** នៅឆ្នាំ២០០៤ មូលដ្ឋានទិន្នន័យជាតិអំពីបទល្មើសព្រហ្មទណ្ឌខាងផ្លូវភេទត្រូវបានបង្កើតឡើងនៅក្រសួងមហាផ្ទៃដើម្បីប្រមូលផ្តុំព័ត៌មានអំពីការរំលោភផ្លូវភេទ ការកេងប្រវ័ញ្ច និងករណីជួញដូរកុមារ ហើយផ្តល់ព័ត៌មានលម្អិតអំពីករណីរបស់ជនរងគ្រោះ និងជនសង្ស័យ ដែលអាចប្រើប្រាស់ជាឧបករណ៍គ្រប់គ្រងករណីនៃបទល្មើស។ ក្រោយមកទៀតទិន្នន័យដាក់បញ្ចូល អំពើហិង្សាក្នុងគ្រួសារទៅក្នុងប្រព័ន្ធទិន្នន័យនេះថែមទៀត។

**៤៨-** នៅឆ្នាំ២០០៦ ក្រសួងយុត្តិធម៌បានបង្កើតប្រព័ន្ធប្រមូលទិន្នន័យ និងប្រព័ន្ធត្រួតពិនិត្យយុត្តិធម៌អនីតិជនរួមទាំងទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ ដើម្បីត្រួតពិនិត្យលើដំណើរការរឿងក្តីរបស់កុមារល្មើសនឹងច្បាប់ និងកុមាររងគ្រោះនៅពេលដែលរឿងក្តីឆ្លងកាត់ដំណាក់កាល និងស្ថាប័នផ្សេងៗនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ក្រសួងយុត្តិធម៌បានអនុវត្តគម្រោងសាកល្បងក្នុងការប្រមូលទិន្នន័យ និងប្រព័ន្ធទិន្នន័យស្តីពីយុត្តិធម៌កុមារនៅក្នុងរាជធានី ខេត្ត ចំនួន ៦ ហើយកំពុងត្រួតពិនិត្យឡើងវិញដើម្បីឱ្យស្របជាមួយនឹងការចុះបញ្ជីនៅតុលាការគំរូ ។

**៤៩-** ក្រសួងមហាផ្ទៃផ្តល់សេវាទូរស័ព្ទអចិន្ត្រៃយ៍នៅក្នុងរាជធានី ខេត្តចំនួន ៧។ ប្រព័ន្ធទិន្នន័យទាក់ទងនឹងបទល្មើសជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទត្រូវបានកែសម្រួលសម្របទៅតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលមានករណីជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារចំនួន ៦៤៨ ករណីត្រូវបានរាយការណ៍ហើយជនជាប់សង្ស័យចំនួន ៤៥៦នាក់ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ២០០៩។ ជនរងគ្រោះជាកុមារចំនួន ៧៧៣នាក់ ត្រូវបានជួយសង្គ្រោះក្នុងនោះ ១៤% ត្រូវបានបញ្ជូនទៅមន្ត្រីសង្គមកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល។

## XI. ការត្រួតពិនិត្យតាមដាន

**៥០-** រាជរដ្ឋាភិបាលបានឱ្យក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលកំពុងធ្វើហិរញ្ញប្បទានដល់សកម្មភាព កម្មវិធី គម្រោងនានាផ្តល់អាទិភាពខ្ពស់ដល់ការត្រួតពិនិត្យតាមដាន និងវាយតម្លៃយ៉ាងទៀងទាត់លើការអនុវត្តផែនការសកម្មភាព កម្មវិធីគម្រោងទាំងនោះ ហើយធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យតាមដាន និង

វាយតម្លៃមកក្រសួងផែនការ ដើម្បីក្រសួងផែនការអាចយកព័ត៌មានដែលបានបង្ហាញនៅក្នុងរបាយការណ៍ទាំងនោះ ដាក់បញ្ចូលនៅក្នុងការវាយតម្លៃរួមលើវឌ្ឍនភាពក្នុងការសម្រេចបានគោលដៅនិងចំណុចដៅនៃការអភិវឌ្ឍ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣[៦] ។ ការត្រួតពិនិត្យតាមដានកិច្ចការយុត្តិធម៌កុមារ ធ្វើឡើងតាមរយៈការចុះរបស់មន្ត្រីថ្នាក់ក្រសួងដល់មូលដ្ឋាន។ ក្រសួងយុត្តិធម៌ និងក្រសួង ស.អ.យ មានតារាងត្រួតពិនិត្យជាជំនួយស្មារតីសម្រាប់មន្ត្រីថ្នាក់កណ្តាល ចុះទៅមូលដ្ឋាន និងមានតារាងត្រួតពិនិត្យសម្រាប់មន្ត្រីជំនាញតាមដានស្ថានភាពនៃករណីឬរឿងក្តី។ ការត្រួតពិនិត្យតាមដានត្រូវបានសម្រួលដោយប្រព័ន្ធទិន្នន័យដែលបានបង្កើតនៅតាមក្រសួង ដូចជា ក្រសួង ស.អ.យ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃជាដើម ។

**៥១-** ក្រៅពីនេះដៃគូអភិវឌ្ឍន៍បានរួមចំណែកយ៉ាងសំខាន់ដល់ការត្រួតពិនិត្យតាមដានស្ថានភាពកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌តាមរយៈបណ្តាញរបស់ខ្លួន ការចែករំលែកផ្លាស់ប្តូរព័ត៌មាន និងការប្រជុំពិគ្រោះយោបល់។

## XII. សហប្រតិបត្តិការនិងការសម្របសម្រួល

**៥២-** កិច្ចសហការនិងការសម្របសម្រួលក្នុងវិស័យយុត្តិធម៌កុមារ ក្នុងចំណោមដៃគូយុត្តិធម៌ព្រហ្មទណ្ឌ ក៏ដូចជាដៃគូអភិវឌ្ឍន៍ប្រព្រឹត្តទៅបានល្អប្រសើរ។ ក្រុមការងារអន្តរក្រសួងដើម្បីយុត្តិធម៌កុមារត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៦ និងបានបំពេញតួនាទីភារកិច្ចរបស់ខ្លួនក្នុងការពិនិត្យកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន

---

[៦] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ ជំពូកទី៦

បង្កើតគោលការណ៍ណែនាំស្តីពីរបៀបដោះស្រាយរឿងក្តីដែលមានជនរងគ្រោះជាកុមារ និងជនល្មើសជាកុមារតាមរបៀបកុមារមេត្រី រៀបចំនិងបង្កើតពិធីសាររួមរវាងក្រសួងពាក់ព័ន្ធស្តីពីការជួយគាំពារផ្នែកច្បាប់ និងផ្នែកសង្គមកិច្ចដល់កុមារ រៀបចំបង្កើតគោលនយោបាយពាក់ព័ន្ធនឹងយុត្តិធម៌កុមារ ព្រមទាំងបន្តតាមដាននិងវាយតម្លៃរាល់គោលនយោបាយនានាដែលបានដាក់ចេញ។ ក្រុមការងារអង្គការមិនមែនរដ្ឋាភិបាលដើម្បីយុត្តិធម៌កុមារត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨ ដើម្បីរួមវិភាគទានក្នុងការធ្វើឱ្យសម្រេចគោលបំណងរួមក្នុងការធានាថា :

១- សិទ្ធិនិងឧត្តមប្រយោជន៍របស់កុមាររងគ្រោះ កុមារល្មើសនឹងច្បាប់និងកុមារជាសាក្សីត្រូវបានការពារ និងលើកស្ទួយនៅក្នុងប្រព័ន្ធយុត្តិធម៌

២- កុមារល្មើសនឹងច្បាប់ត្រូវបានបង្វែរចេញពីប្រព័ន្ធយុត្តិធម៌ ត្រូវបានស្តារនីតិសម្បទាពេញលេញ និងត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍និងក្រុមគ្រួសារវិញក្រោយពីការផ្តន្ទាទោសឬឃុំខ្លួន ឬចាកចេញពីមណ្ឌលស្តារនីតិសម្បទា។

**៥៣-** ការសម្របសម្រួលនិងធ្វើសហប្រតិបត្តិការក្នុងវិស័យយុត្តិធម៌កុមារ ជាពិសេសទាក់ទងនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទត្រូវបានពង្រឹងបន្ថែមតាមរយៈការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារដែលស្ថិតក្រោមការដឹកនាំនិងសម្របសម្រួលរបស់ក្រសួងមហាផ្ទៃ ក្រុមការងារជាតិស្តីពីគំនិតផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ (ខមមីត)

ដែលស្ថិតក្រោមការដឹកនាំ និងសម្របសម្រួលរបស់ក្រសួងកិច្ចការនារី និងក្រុមពិគ្រោះយោបល់ដែលមានសមាសភាពមកពីដៃគូអភិវឌ្ឍន៍។

**៥៤-** ចាប់តាំងពីឆ្នាំ២០០៦ មកក្រសួងយុត្តិធម៌បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីយុត្តិធម៌កុមារ ដោយមានការចូលរួមពីសំណាក់ភ្នាក់ងារនៃយុត្តិធម៌ព្រហ្មទណ្ឌមកពីរាជធានី ខេត្ត តំណាងកុមារ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពង្រឹងកិច្ចសហការ វាយតម្លៃអំពីតួនាទីភារកិច្ចរបស់ភ្នាក់ងារទាំងនោះ និងស្នើឡើងសកម្មភាពក្នុងពេលអនាគត។

**៥៥-** នៅឆ្នាំ២០១០ នេះដោយមានការប្រឹងប្រែងក្នុងការបង្កើតឱ្យមានក្របខ័ណ្ឌច្បាប់ និងការអនុវត្តច្បាប់បានល្អប្រសើរជាងពេលកន្លងមកថ្មីៗនេះ ព្រះរាជាណាចក្រកម្ពុជាត្រូវបានសហរដ្ឋអាមេរិកចាត់ថ្នាក់ទៅក្នុងប្រទេសកម្រិតទី២ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ។

**៥៦-** ដើម្បីឱ្យក្រសួងនិងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសហការគ្នាអនុវត្តប្រព័ន្ធយុត្តិធម៌កុមារមេត្រី ដែលមានលក្ខណៈទូលំទូលាយដើម្បីធានាការពារ និងលើកស្ទួយឧត្តមប្រយោជន៍របស់កុមាររងគ្រោះ កុមារប្រឈមនឹងគ្រោះថ្នាក់និងកុមារល្មើសនឹងច្បាប់ និងពង្រឹងសហប្រតិបត្តិការនិងការសម្របសម្រួលអនុវត្តវិធីសាស្ត្រអន្តរវិស័យនៃប្រព័ន្ធយុត្តិធម៌ កុមារមេត្រីនៅគ្រប់ដំណាក់កាលនៃចំណាត់ការរឿងក្តីដែលពាក់ព័ន្ធនឹងអនីតិជន ក្រុមការងារអន្តរក្រសួងបានរៀបចំឱ្យមានសេចក្តីព្រាងបទបញ្ញាមួយដែលហៅថា " ប្រកាសអន្តរក្រសួងស្តីពីកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងដំណើរការយុត្តិធម៌កុមារ "។

## XIII. សន្និដ្ឋាន

**៥៧**- ប្រព័ន្ធការពារផ្នែកសង្គមនិងកិច្ចការពារកុមារនៅកម្ពុជានៅមានកម្រិត។ កម្ពុជាត្រូវការធនធានចាំបាច់ដើម្បីអនុវត្តកម្មវិធីយុត្តិធម៌កុមារ ដូចជា ការអង្កេតថ្នាក់ជាតិដ៏ទូលំទូលាយមួយលើកុមាររងគ្រោះនិងកុមារល្មើសនឹងច្បាប់ ការបង្ការបទល្មើស និងការអនុវត្តជម្រើសនានាជំនួសការយកកុមារទៅដាក់ពន្ធនាគារ។ ក្រៅពីនេះនៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ដូចជា ការកសាងនិងពង្រឹងសមត្ថភាពរបស់ភ្នាក់ងារសង្គមកិច្ចនិងអ្នកធ្វើនីតិកោសល្យវិច្ច័យ និងទំនើបកម្មឧបករណ៍ធ្វើកោសល្យវិច្ច័យ។

**៥៨**- សកម្មភាពផ្សេងៗទៀតដែលកម្ពុជានឹងធ្វើរួមមាន ៖

- រៀបចំផែនការសកម្មភាពជាតិស្តីពីកំណែទម្រង់យុត្តិធម៌កុមារ និងការបង្ការអនីតិជនពីការប្រព្រឹត្តល្មើសនឹងច្បាប់។
- បង្កើនល្បឿនអនុម័តគោលការណ៍ណែនាំស្តីពីនីតិវិធីដោះស្រាយរឿងក្តីកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដោយគិតគូរដល់ចំណុចរសើបរបស់កុមារ។
- ជំរុញការប្រើប្រាស់របាំងក្នុងបន្ទប់សវនាការ ឧបករណ៍ភ្ជាប់បណ្តាញទូរទស្សន៍ និងសម្ភារៈជំនួយដល់ការយកសក្ខីកម្មកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌។
- លើកស្ទួយការប្រើមធ្យោបាយជំនួសការឃុំខ្លួននិងការដាក់ពន្ធនាគារ និងមធ្យោបាយជំនួសដែលមិនឃុំខ្លួនផ្សេងៗ ទៀតសម្រាប់កុមារប្រព្រឹត្តល្មើសនឹងច្បាប់ អនុលោមទៅតាមក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ។
- លើកស្ទួយការយល់ដឹងពីការបង្វែរ និងការស្តារស្ថានភាពយុត្តិធម៌ ដូចមានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ។

- លើកស្ទួយ និងគាំទ្រដល់កម្មវិធីបង្ការអនីតិជនពីការប្រព្រឹត្តល្មើសនឹងច្បាប់ នៅតាមសហគមន៍ និងគ្រួសារ និងកម្មវិធី ស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មនៅតាមសហគមន៍សម្រាប់កុមារប្រព្រឹត្តល្មើសនឹងច្បាប់ ជាពិសេសការប្រឹងប្រែងក្នុងការរក្សាកុមារឱ្យនៅក្នុងគ្រួសារ និងការបង្រួបបង្រួមកុមារជាមួយគ្រួសារ ។

**ឧបសម្ព័ន្ធ :**

របាយការណ៍លើកទី២ និងទី៣ របស់កម្ពុជា ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ឆ្នាំ ២០០០ ដល់ ២០០៧ ។